厚生労働省 ひと、くらし、みらいのために
Ministry of Health, Labour and Welfare

កំណែប្រែជាភាសាខ្មែរ / クメール語版

# អំពីការប្រើប្រាស់កាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព

កំណែប្រែជាភាសាខ្មែរ (គិតត្រឹមខែកក្កដា ឆ្នាំ 2025)

នាយកដ្ឋានធានារ៉ាប់រងនៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
Ministry of Health, Labour and Welfare of Japan

# ទិដ្ឋភាពទូទៅនៃប្រព័ន្ធធានារ៉ាប់រងសេវាវេជ្ជសាស្ត្ររបស់ជប៉ុន

ក្នុងប្រព័ន្ធធានារ៉ាប់រងសេវាវេជ្ជសាស្ត្ររបស់ជប៉ុន អ្នកដែលចូលជាគោលដៅចុះឈ្មោះចូលទាំងអស់ តាមរយៈការបង់បុព្វលាភ នឹងអាចទទួលបានសេវាវេជ្ជសាស្ត្រដោយរ៉ាប់រងបន្ទុកផ្ទាល់ខ្លួនក្នុងកម្រិតមួយ។ អ្នកដែលចូលជាគោលដៅចុះឈ្មោះចូល មិនមែនតែប្រជាជនជប៉ុនប៉ុណ្ណោះទេ គឺរួមបញ្ចូលទាំងជនបរទេសដែលចូលលក្ខខណ្ឌតម្រូវក្នុងកម្រិតមួយដូចជា អ្នកដែលមានរយៈពេលស្នាក់នៅលើស 3 ខែជាដើម។
ពេលទទួលសេវាវេជ្ជសាស្ត្រជាក់ស្តែង អ្នកដែលចូលជាគោលដៅចុះឈ្មោះចូល អាចជ្រើសរើសបានដោយសេរីនូវស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានដែលចង់ទៅពិនិត្យជំងឺ។



# ការពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិនៃធានារ៉ាប់រងសុខភាពនៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថាន

អាចទទួលការពិនិត្យជំងឺដោយរ៉ាប់រងបន្ទុកផ្ទាល់ខ្លួន 10% ទៅ 30% តាមរយៈការពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិដោយប្រើកាតលេខបុគ្គល (My Number Card)ជាដើម។

## ការពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិនៃធានារ៉ាប់រងសុខភាពនៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថាន

ពេលទទួលការពិនិត្យជំងឺនៅស្ថាប័នវេជ្ជសាស្ត្រ ឬឱសថស្ថាន នឹងត្រូវបានពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិដោយឯកសារណាមួយក្នុងចំណោម

- **កាតលេខបុគ្គល** (My Number Card)
- **បណ្ណធានារ៉ាប់រងសុខភាព** *
- **លិខិតពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិ** * ។

(*) ចំពោះអ្នកដែលមិនមានកាតលេខបុគ្គល (My Number Card) និងអ្នកដែលមិនបានចុះឈ្មោះប្រើប្រាស់កាតលេខបុគ្គល (My Number Card)ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព គឺអាចប្រើបណ្ណធានារ៉ាប់រងសុខភាព (យ៉ាងយូរត្រឹមថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2025) ឬលិខិតពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិ (ចេញជូនចាប់ពីថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2024 ទៅ)។

តាមរយៈការធ្វើបែបនោះ នឹងអាចទទួលការពិនិត្យជំងឺដោយមិនចាំបាច់រ៉ាប់រងបន្ទុក 100% នៃថ្លៃសេវាវេជ្ជសាស្ត្រដែលត្រូវចំណាយជាក់ស្តែង គឺរ៉ាប់រងបន្ទុកផ្ទាល់ខ្លួន **30% ចំពោះអ្នកដែលមានអាយុពី 6 ឆ្នាំទៅ 69 ឆ្នាំ**។
ចំពោះអ្នកផ្សេងទៀតក៏អាចទទួលការពិនិត្យជំងឺដោយរ៉ាប់រងបន្ទុក 10%, 20% ឬ 30% អាស្រ័យលើអាយុ និងប្រាក់ចំណូលរបស់ពួកគេ។

**កាតលេខបុគ្គល (My Number Card)**




**បណ្ណធានារ៉ាប់រងសុខភាព (រហូតដល់ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2025)**




**លិខិតពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិ (ចាប់ពីថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2024)**



# អំពីរបៀបទទួលបានកាតលេខបុគ្គល (My Number Card)

របៀបស្នើសុំដើម្បីទទួលបានកាតលេខបុគ្គល (My Number Card) មាន 4 យ៉ាង។

## ទូរសព្ទស្មាតហ្វូន (មានតែភាសាជប៉ុន)

1. ថតរូបថតមុខដោយទូរសព្ទស្មាតហ្វូន (អាចថតពេលកំពុងធ្វើបែបបទក៏បាន)
2. ប្រើទូរសព្ទស្មាតហ្វូនស្កេន**កូដ QR សម្រាប់ស្នើសុំចេញកាតជូន** ដែលមានក្នុងលិខិតជូនដំណឹងអំពីលេខបុគ្គល (My Number Card)
3. ចុះអាសយដ្ឋានអ៊ីមែលជាដើមនៅលើវេបសាយសម្រាប់អ្នកស្នើសុំដែលត្រូវបានបង្ហាញ
4. នៅពេលដែល URL នៃវេបសាយសម្រាប់អ្នកស្នើសុំត្រូវបានបញ្ជូនដល់អាសយដ្ឋានអ៊ីមែល ត្រូវបញ្ចូលរូបថតមុខហើយបញ្ចូលព័ត៌មានចាំបាច់ដើម្បីបញ្ចប់ការស្នើសុំ




**កូដ QR សម្រាប់ស្នើសុំចេញកាតជូន**

## ម៉ាស៊ីនថតរូបថតបិទកាត

1. ជ្រើសរើស "ស្នើសុំកាតលេខបុគ្គល (My Number Card) " ពីផ្ទាំងចុច
2. បញ្ចូលថ្លៃសេវាថតរូប ហើយដាក់ឲ្យម៉ាស៊ីនស្កេនបារកូដស្កេន**កូដ QR សម្រាប់ស្នើសុំចេញកាតជូន** ដែលមានក្នុងលិខិតជូនដំណឹងអំពីលេខបុគ្គល (My Number)
3. បញ្ចូលព័ត៌មានចាំបាច់តាមការណែនាំក្នុងអេក្រង់
4. ថតរូបថតមុខហើយចុចបញ្ជូនដើម្បីបញ្ចប់ការស្នើសុំដោយធ្វើតាមការណែនាំលើអេក្រង់




**កូដ QR សម្រាប់ស្នើសុំចេញកាតជូន**

## កុំព្យូទ័រ (មានតែភាសាជប៉ុន)

1. ថតរូបថតមុខដោយប្រើកាមេរ៉ាឌីជីថលជាដើម
2. បញ្ចូល**ID ពាក្យស្នើសុំ (23 ខ្ទង់)** ហើយចុះអាសយដ្ឋានអ៊ីមែលនៅលើវេបសាយសម្រាប់ស្នើសុំ *
3. នៅពេលដែល URL នៃវេបសាយសម្រាប់អ្នកស្នើសុំត្រូវបានបញ្ជូនដល់ ត្រូវបញ្ចូលរូបថតមុខហើយបញ្ចូលព័ត៌មានចាំបាច់ដើម្បីបញ្ចប់ការស្នើសុំ


マイナンバーカードの申請について

○ マイナンバーカードの申請にはスマートフォンやタブレットによるオンライン申請が便利です。顔写真データをご準備のうえ、右記のQRコードを読み取ってください。

○ 郵送によりマイナンバーカードを申請する場合には、同梱の封筒と交付申請書をご利用ください。その他の申請方法については同梱のパンフレットをご確認ください。

※ なお、マイナンバーカードを申請した場合、申請状況の問
あなたの申請書IDは【 1234 5678 9012 3456 7890 123 】です

○ マイナンバーカードの受け取りには本人確認が必要ですが
認を行う場合には、本通知書を提示することで、手続が簡素
ります。マイナンバーカードの申請に関する詳細については、
またはマイナンバーカード総合サイト（https://www.kojinb
をご覧ください。

**ID ពាក្យស្នើសុំ (23 ខ្ទង់)**

*( https://net.kojinbango-card.go.jp/ )

## ប្រៃសណីយ៍

1. បំពេញព័ត៌មានចាំបាច់ក្នុងពាក្យស្នើសុំចេញកាតជូនដែលដាក់ក្នុងស្រោមសំបុត្រជាមួយលិខិតជូនដំណឹងអំពីលេខបុគ្គល (My Number) ហើយបិទរូបថតមុខដែលបានថត**មិនយូរជាង 6 ខែ**
2. ដាក់ចូលស្រោមសំបុត្រសម្រាប់ផ្ញើត្រឡប់ដែលមានក្នុងស្រោមសំបុត្រជាមួយគ្នា ហើយផ្ញើតាមប្រៃសណីយ៍ដើម្បីបញ្ចប់ការស្នើសុំ



**ពាក្យស្នើសុំចេញកាតជូន**



**រូបថតមុខ**



**ស្រោមសំបុត្រសម្រាប់ផ្ញើត្រឡប់**

ចំពោះពាក្យស្នើសុំចេញជូនកាតលេខបុគ្គល (My Number Card) ជាភាសាផ្សេងក្រៅពីភាសាជប៉ុន សូមមើលវេបសាយ
**កូដ QR សម្រាប់ចូលទៅវេបសាយគឺត្រង់នេះ:⇒**

* ចំពោះព័ត៌មានពាក់ព័ន្ធនឹងការទាញយកពាក្យស្នើសុំនិងកាតលេខបុគ្គល (My Number Card) សូមពិនិត្យនៅវេបសាយខាងក្រោម។
(មានជាភាសាជប៉ុន អង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ ព័រទុយហ្គាល់)
https://www.kojinbango-card.go.jp/

# ការចុះឈ្មោះប្រើប្រាស់កាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព

ដើម្បីប្រើកាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព ចាំបាច់ត្រូវចុះឈ្មោះប្រើប្រាស់។ របៀបមានដូចខាងក្រោម។

## 1) ការចុះឈ្មោះនៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថាន

របៀបចុះឈ្មោះនៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថាន មានដូចខាងក្រោម។ សូមធ្វើតាមជំហាន។

### របស់ដែលត្រូវការ

- កាតលេខបុគ្គល (My Number Card)

1




សូមជ្រើសរើស "ចុះឈ្មោះ"។

2




សូមពិនិត្យបញ្ជាក់លក្ខខណ្ឌប្រើប្រាស់បញ្ជរអនឡាញលេខបុគ្គល (Mynaportal) ហើយបើគ្មានបញ្ហា សូមជ្រើសរើស "ឯកភាពហើយបន្តទៅបន្ទាប់"។

3




ការចុះឈ្មោះប្រើប្រាស់កាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាពគឺបានសម្រេចហើយ។
សូមជ្រើសរើស "ទៅបន្ទាប់" ហើយបន្តទៅអេក្រង់ឯកភាព។

# ការចុះឈ្មោះប្រើប្រាស់កាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព

ដើម្បីប្រើកាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព ចាំបាច់ត្រូវចុះឈ្មោះប្រើប្រាស់។ របៀបមានដូចខាងក្រោម។

## 2) ការចុះឈ្មោះទុកជាមុននៅ បញ្ជរអនឡាញលេខបុគ្គល(Mynaportal)

### របស់ដែលត្រូវការ

- កាតលេខបុគ្គល (My Number Card)
- ពាក្យសម្ងាត់សម្រាប់បញ្ជាក់អ្នកប្រើប្រាស់
- ទូរសព្ទស្មាតហ្វូន
- ដំឡើងកម្មវិធី Mynaportal

### ជំហាននៃការចុះឈ្មោះ

* សូមចុះឈ្មោះតាមជំហានខាងក្រោមស្របតាមរូបភាពនៅអេក្រង់។

① បើកកម្មវិធី Mynaportal ឡុកអ៊ីនចូល ហើយនៅត្រង់ "លិខិតបញ្ជាក់" ត្រូវជ្រើសរើស "បណ្ណធានារ៉ាប់រងសុខភាព"។

② បើ "ការប្រើប្រាស់កាតលេខបុគ្គល (My Number Card) " គឺសរសេរជាពណ៌ក្រហមថា "មិនទាន់ចុះឈ្មោះ" ត្រូវជ្រើសរើស "ចុះឈ្មោះ"។

③ បើការចុះឈ្មោះត្រូវការពេលវេលា វានឹងបង្ហាញថា "កំពុងចុះឈ្មោះ"។

④ បើ "ការប្រើប្រាស់កាតលេខបុគ្គល (My Number Card) " បានប្រែទៅជា "ចុះឈ្មោះរួចរាល់" នោះការចុះឈ្មោះប្រើប្រាស់គឺបានសម្រេចហើយ។

### ឡុកអ៊ីនចូលបញ្ជរអនឡាញលេខបុគ្គល Mynaportal

- ដំឡើង "កម្មវិធី Mynaportal"
- ដើម្បីឡុកអ៊ីនចូល ត្រូវប្រើកាតលេខបុគ្គល (My Number Card) របស់សាមីខ្លួនអ្នកដាក់ពាក្យ

iOS

Android



បើមិនអាចស្កែនកូដ QR បាន សូមស្វែងរកដោយពាក្យ "Mynaportal"។

[រូបភាពអេក្រង់]



# របៀបទទួលការពិនិត្យជំងឺដោយប្រើកាតលេខបុគ្គល (My Number Card)

ពេលទទួលការពិនិត្យជំងឺនៅស្ថាប័នវេជ្ជសាស្ត្រ ឬឱសថស្ថានដោយប្រើកាតលេខបុគ្គល (My Number Card) ដែលបានចុះឈ្មោះប្រើប្រាស់ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព នឹងត្រូវបានពិនិត្យបញ្ជាក់អត្តសញ្ញាណសាមីខ្លួននិងពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិ ដោយម៉ាស៊ីនស្កេនកាតដែលភ្ជាប់មុខងារផ្ទៀងផ្ទាត់មុខ *។

* ម៉ាស៊ីនស្កេនកាតដែលភ្ជាប់មុខងារផ្ទៀងផ្ទាត់មុខ គឺជាម៉ាស៊ីនស្កេនកាតដែលអាចពិនិត្យបញ្ជាក់អត្តសញ្ញាណសាមីខ្លួនដោយស្កេនទិន្នន័យរូបថតមុខនៃកាតលេខបុគ្គល (My Number Card) តាមរយៈបន្ទះឈីប IC ហើយផ្ទៀងផ្ទាត់ "ទិន្នន័យរូបថតមុខ" នោះនឹង "រូបថតមុខសាមីខ្លួន" ដែលបានថតនៅបញ្ជរ។

## នៅពេទ្យ

①ដាក់កាតលេខបុគ្គល (My Number Card)



### ប្រភេទនៃម៉ាស៊ីនស្កេនកាតដែលភ្ជាប់មុខងារផ្ទៀងផ្ទាត់មុខ



## ពិនិត្យបញ្ជាក់អត្តសញ្ញាណសាមីខ្លួន

②ជ្រើសរើសរបៀបពិនិត្យបញ្ជាក់អត្តសញ្ញាណសាមីខ្លួន

**ផ្ទៀងផ្ទាត់មុខ**



**លេខកូដ PIN (4 ខ្ទង់)**




* ទីតាំងលេខនឹងផ្លាស់ប្តូរ

## ពិនិត្យបញ្ជាក់ចំណុចដែលឯកភាព

③ពិនិត្យបញ្ជាក់និងជ្រើសរើសទាក់ទងនឹងការប្រើប្រាស់ព័ត៌មានអំពីការពិនិត្យព្យាបាល ថ្នាំពេទ្យ ការពិនិត្យសុខភាពកំណត់ពិសេសជាដើម។

* ក្រៅពីនេះក៏អាចមានចំណុចត្រូវពិនិត្យបញ្ជាក់ឬចំណុចដែលឯកភាពផ្សេងទៀតដូចជាវេជ្ជបញ្ជាអេឡិចត្រូនិចជាដើមផងដែរ។




## ការទទួលបានសម្រេចហើយ

④បើអេក្រង់ខាងក្រោមលេចចេញ នោះការទទួលគឺបានសម្រេចហើយ។



# អំពីចំណុចដែលឯកភាព

នៅពេលទទួលដោយម៉ាស៊ីនស្កែនកាតដែលភ្ជាប់មុខងារផ្ទៀងផ្ទាត់មុខ នឹងមានការពិនិត្យបញ្ជាក់ការឯកភាពថាព្រមផ្តល់ព័ត៌មានអំពីថ្នាំពេទ្យដែលត្រូវបានចេញវេជ្ជបញ្ជានិងការពិនិត្យសុខភាពកំណត់ពិសេសជាដើមរបស់អ្នកកាលពីមុន ដល់គ្រូពេទ្យឬឱសថការីឬទេ។

## ការពិនិត្យបញ្ជាក់របៀបឯកភាព

過去の医療情報等の提供に同意しますか。【手術 / 診療、お薬 / 検診】

តើអ្នកឯកភាពផ្តល់ព័ត៌មានសេវាវេជ្ជសាស្ត្រជាដើមរបស់អ្នកកាលពីមុនទេ? [ការវះកាត់/ពិនិត្យព្យាបាល ថ្នាំពេទ្យ/តេស្តពិនិត្យសុខភាព]

- 全て同意する / ឯកភាពទាំងអស់
- 個別に同意する / ឯកភាពដាច់ៗពីគ្នា

## ● អេក្រង់ឯកភាពដាច់ៗពីគ្នា

| ការវះកាត់ | ព័ត៌មានអំពីការពិនិត្យព្យាបាល/ថ្នាំពេទ្យក្រៅពីការវះកាត់ | ព័ត៌មានអំពីថ្នាំពេទ្យ | ព័ត៌មានអំពីការពិនិត្យសុខភាព |
|---|---|---|---|
| 過去の手術情報を、当機関に提供することに同意しますか。 | 過去の手術以外の診療・お薬情報を、当機関に提供することに同意しますか。 | 過去のお薬情報を当機関に提供することに同意しますか。 | 過去の健診情報を、当機関に提供することに同意しますか。 |
| តើអ្នកឯកភាពផ្តល់ព័ត៌មានអំពីការវះកាត់របស់អ្នកកាលពីមុនដល់ស្ថាប័ននេះទេ? | តើអ្នកឯកភាពផ្តល់ព័ត៌មានអំពីការពិនិត្យព្យាបាល/ថ្នាំពេទ្យក្រៅពីការវះកាត់របស់អ្នកកាលពីមុនដល់ស្ថាប័ននេះទេ? | តើអ្នកឯកភាពផ្តល់ព័ត៌មានអំពីថ្នាំពេទ្យរបស់អ្នកកាលពីមុនដល់ស្ថាប័ននេះទេ? | តើអ្នកឯកភាពផ្តល់ព័ត៌មានអំពីការពិនិត្យសុខភាពរបស់អ្នកកាលពីមុនដល់ស្ថាប័ននេះទេ? |
| ឯកភាព 同意する | ឯកភាព 同意する | ឯកភាព 同意する | ឯកភាព 同意する |
| មិនឯកភាព 同意しない | មិនឯកភាព 同意しない | មិនឯកភាព 同意しない | មិនឯកភាព 同意しない |

* ការរចនាអេក្រង់និងអត្ថបទដែលបង្ហាញចេញ គឺខុសគ្នាទៅតាមស្ថាប័នវេជ្ជសាស្ត្រ/ក្រុមហ៊ុនផលិត។

### ឯកភាពទាំងអស់

បើអ្នកគ្មានបញ្ហាក្នុងការផ្តល់ព័ត៌មានអំពីសេវាវេជ្ជសាស្ត្រជាដើមរបស់អ្នកកាលពីមុនទាំងអស់ទេនោះ សូមជ្រើសរើសប៊ូតុងនៅលើ។ **វានឹងបញ្ចប់ការឯកភាពសរុបទាំងអស់ក្នុងពេលតែមួយ។**

### ឯកភាពដាច់ៗពីគ្នា

បើអ្នកចង់សម្រាំងព័ត៌មានដែលត្រូវផ្តល់ សូមជ្រើសរើសប៊ូតុងនៅក្រោម។ បន្ទាប់មក វានឹងបង្ហាញចេញតាមលំដាប់អំពីការផ្តល់ព័ត៌មានពីការវះកាត់និងថ្នាំពេទ្យ ព័ត៌មានអំពីការពិនិត្យសុខភាពជាដើម ដូច្នេះសូមជ្រើសរើសការឯកភាពដាច់ៗពីគ្នា។

# អំពីចំណុចដែលឯកភាព (ករណីបានទៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានដដែលម្តងទៀត)

ចំពោះអេក្រង់ទទួលយកការឯកភាពរបស់ម៉ាស៊ីនស្កែនកាតពេលទទួល នៅពេលអ្នក**ទៅ**ស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានដែលបានទៅកាលពីកន្លងមក**ម្តងទៀត** ស្ថានភាពនៃការឯកភាពកាលពីលើកមុនដែលបានចុះដាច់ៗពីគ្នានៅស្ថាប័ននោះ នឹងអាចផ្ទេរបន្តបាន ។
* មិនមានការចែករំលែកស្ថានភាពនៃការឯកភាពទៅកាន់ស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានផ្សេងទៀតទេ។




● **អេក្រង់ឯកភាពដាច់ៗពីគ្នា** ៖ អេក្រង់ឯកភាពដាច់ៗពីគ្នា ៖ អេក្រង់ឯកភាពដាច់ៗពីគ្នានឹងបង្ហាញចេញអេក្រង់ដូចគ្នានឹងអេក្រង់នៅទំព័រទី 14។

## ក្នុងករណីឯកភាពដាច់ៗពីគ្នា អាចផ្ទេរបន្តព័ត៌មានដែលឯកភាពពីលើកមុនបាន

❶៖ អាចពិនិត្យបញ្ជាក់ឬកែប្រែស្ថានភាពនៃការឯកភាពពីលើកមុនដោយចុច "ឯកភាពដាច់ៗពីគ្នា"
❷៖ ករណីមានព័ត៌មានដែលឯកភាពដែលបានចុះកាលពីមុន អាចពិនិត្យបញ្ជាក់អំពីស្ថានភាពនៃការឯកភាពនោះបាន
❸៖ ការឯកភាពនឹងបញ្ចប់ដោយខ្លឹមសារដូចគ្នានឹងព័ត៌មានដែលឯកភាពពីលើកមុន ដោយចុច "ផ្ទេរបន្តព័ត៌មានដែលឯកភាពបច្ចុប្បន្ន"
❹៖ អាចកែប្រែផ្សេងពីព័ត៌មានដែលឯកភាពលើកមុន (នឹងក្លាយជាព័ត៌មានដែលឯកភាពពាក់ព័ន្ធនឹងការមកលើកនេះ) ដោយចុច "ជ្រើសរើសឡើងវិញ"

* ការរចនាអេក្រង់និងអត្ថបទដែលបង្ហាញចេញ គឺខុសគ្នាទៅតាមស្ថាប័នវេជ្ជសាស្ត្រ/ក្រុមហ៊ុនផលិត។

# អត្ថប្រយោជន៍នៃការពិនិត្យជំងឺដោយប្រើកាតលេខបុគ្គល (My Number Card)

អត្ថប្រយោជន៍ចម្បងនៃការពិនិត្យជំងឺដោយប្រើកាតលេខបុគ្គល (My Number Card) មានដូចខាងក្រោម។




## អាចទទួលបានសេវាវេជ្ជសាស្ត្រ កាន់តែល្អដែលផ្អែកលើទិន្នន័យ

បើអ្នកឯកភាពនឹងការផ្តល់ព័ត៌មានអំពីថ្នាំពេទ្យជាដើម នោះនឹងអាចចែករំលែកព័ត៌មានអំពីថ្នាំពេទ្យដែលត្រូវបានចេញវេជ្ជបញ្ជានិងការពិនិត្យសុខភាពកំណត់ពិសេសជាដើមកាលពីមុនដល់គ្រូពេទ្យ/ឱសថការីបានដោយរលូនទោះបីពិនិត្យជំងឺលើកដំបូងក៏ដោយ ដោយមិនចាំបាច់បង្ហាញសៀវភៅកំណត់ត្រាប្រើប្រាស់ថ្នាំពេទ្យ។




## ត្រូវបានលើកលែងការបង់ប្រាក់ដែលលើសកម្រិតកំណត់នៃចំណាយព្យាបាលខ្ពស់ ដោយមិនចាំបាច់ធ្វើបែបបទ

ត្រូវបានលើកលែងការបង់ប្រាក់ដែលលើសកម្រិតកំណត់នៃចំណាយព្យាបាលខ្ពស់ដោយមិនចាំបាច់យកតាមខ្លួននូវវិញ្ញាបនបត្របញ្ជាក់ជាក្រដាសនិងមិនចាំបាច់ធ្វើបែបបទដោយសារធ្វើការពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិដោយកាតលេខបុគ្គល (My Number Card) ។

### អ្វីទៅជា "ប្រព័ន្ធចំណាយព្យាបាលខ្ពស់"?

ប្រព័ន្ធចំណាយព្យាបាលខ្ពស់គឺជាប្រព័ន្ធដែលទូទាត់សងទឹកប្រាក់ដែលអ្នកបង់លើសក្នុងករណីដែលទឹកប្រាក់ដែលបានបង់នៅបញ្ជរនៃស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានក្នុងមួយខែ (ចាប់ពីដើមដល់ចុងខែ) លើសពីកម្រិតកំណត់។ ប្រព័ន្ធចំណាយព្យាបាលខ្ពស់នឹងត្រូវបានអនុវត្តដោយការពិនិត្យបញ្ជាក់លក្ខណៈសម្បត្តិតាមរយៈកាតលេខបុគ្គល (My Number Card) ។

# ករណីមិនអាចត្រូវបានទទួលដោយប្រើកាតលេខបុគ្គល (My Number Card)

នៅពេលប្រើកាតលេខបុគ្គល (My Number Card) ធ្វើជាបណ្ណធានារ៉ាប់រងសុខភាព ទាំងក្នុងករណីដែលមិនអាចពិនិត្យបញ្ជាក់លក្ខណ:សម្បត្តិដោយសារហេតុផលណាមួយដូចជាម៉ាស៊ីនស្កែនកាតដែលភ្ជាប់មុខងារផ្ទៀងផ្ទាត់មុខមានបញ្ហាជាដើម ការពិនិត្យបញ្ជាក់លក្ខណ:សម្បត្តិនឹងត្រូវធ្វើឡើងដោយវិធីដូចខាងក្រោម។
ការធ្វើបែបនោះនឹងអាចទទួលការពិនិត្យជំងឺដោយរ៉ាប់រងបន្ទុកផ្ទាល់ខ្លួនដូចកន្លងមកបានដោយមិនត្រូវរ៉ាប់រងបន្ទុកផ្ទាល់ខ្លួន 100% ឡើយ។



បានបង្ហាញកាតលេខបុគ្គល (My Number Card) ប៉ុន្តែ **មិនអាចត្រូវបានទទួល**

## ករណីអាចបង្ហាញមួយក្នុងចំណោមពីរខាងក្រោម

### អេក្រង់ Mynaportal

*ឯកសារ PDF ដែលបានទាញយកពី Mynaportal ក៏អាចបានដែរ




### សេចក្តីជូនដំណឹងអំពីព័ត៌មានលក្ខណ:សម្បត្តិ




**ករណីមិនអាចបង្ហាញទាំងពីរដែលនៅខាងឆ្វេង**

### ករណីពិនិត្យជំងឺម្តងទៀត

#### ការពិនិត្យបញ្ជាក់ផ្ទាល់មាត់

បើខាងស្ថាប័នវេជ្ជសាស្ត្រដឹងពីព័ត៌មានចាំបាច់សម្រាប់ពិនិត្យបញ្ជាក់លក្ខណ:សម្បត្តិ នោះបុគ្គលិកនឹងពិនិត្យបញ្ជាក់ផ្ទាល់មាត់



### ករណីពិនិត្យជំងឺលើកដំបូង

#### លិខិតប្រកាសលក្ខណ:សម្បត្តិអ្នកត្រូវបានធានារ៉ាប់រង




* សូមទទួលទម្រង់បែបបទពីបុគ្គលិក ហើយបំពេញវា

### អ្វីទៅជា "សេចក្តីជូនដំណឹងអំពីព័ត៌មានលក្ខណ:សម្បត្តិ"?

ជាឯកសារដែលត្រូវបានផ្តល់ដល់អ្នកដែលមានបណ្ណធានារ៉ាប់រងលេខបុគ្គល (My Number) ដោយមិនចាំបាច់ស្នើសុំ។ ឯកសារនេះតែឯងគឺមិនអាចទទួលការពិនិត្យជំងឺបានទេ។ បើមិនអាចពិនិត្យបញ្ជាក់លក្ខណ:សម្បត្តិដោយហេតុផលណាមួយ សូមបង្ហាញវារួមជាមួយនិងកាតលេខបុគ្គល (My Number Card) ។

### អ្វីទៅជា "លិខិតប្រកាសលក្ខណ:សម្បត្តិអ្នកត្រូវបានធានារ៉ាប់រង"?

នេះគឺជាឯកសារដែលអ្នកត្រូវបំពេញនៅពេលមិនមានអេក្រង់ Mynaportal ឬសេចក្តីជូនដំណឹងអំពីព័ត៌មានលក្ខណ:សម្បត្តិ បន្ទាប់ពីមិនអាចពិនិត្យបញ្ជាក់លក្ខណ:សម្បត្តិដោយហេតុផលណាមួយនៅស្ថាប័នវេជ្ជសាស្ត្រ/ឱសថស្ថានដែលទៅពិនិត្យជំងឺលើកដំបូង។

# អំពីមជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទ (អាចប្រើភាសាបរទេស)

បើអ្នកមានចម្ងល់ឬជួបបញ្ហាទាក់ទងនឹងកាតលេខបុគ្គល (My Number Card) សូមសាកសួរតាមទូរសព្ទទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទខាងក្រោម។
* ការហៅចេញខុសកំពុងកើនឡើង។ សូមពិនិត្យបញ្ជាក់លេខមុននឹងខល។

## ① អំពីកាតលេខបុគ្គល (My Number Card) ការជូនដំណឹងពីលេខបុគ្គល កាតជូនដំណឹង

## ② អំពីការផ្អាកការប្រើប្រាស់បណ្ណោះអាសន្នដោយសារការបាត់បង់ឬត្រូវបានលួចជាដើមនៃកាតលេខបុគ្គល (My Number Card) ឬទូរសព្ទស្មាហ្វូនដែលផ្ទុកលិខិតបញ្ជាក់អេឡិចត្រូនិក

**0120-0178-27**

### ម៉ោងទទួល

ភាសាអង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ ព័រទុយហ្គាល់

**រៀងរាល់ថ្ងៃ 8:30 - 20:00**

ភាសាថៃ នេប៉ាល់ ឥណ្ឌូនេស៊ី វៀតណាម តាកាឡុក

**រៀងរាល់ថ្ងៃ 9:00-18:00**

**※ចំពោះការផ្អាកការប្រើប្រាស់បណ្ណោះអាសន្នត្រង់ 2) គឺឆ្លើយតប 24 ម៉ោង**

※ បើមិនអាចភ្ជាប់ទៅលេខខាងលើបាន៖ **0570-064-738** (គិតថ្លៃហៅចេញ)
※ បើមិនអាចភ្ជាប់ទៅលេខទាំងអស់ខាងលើ៖ **050-3818-1250** (គិតថ្លៃហៅចេញ)
※ បើអ្នកចង់បានការឆ្លើយតបជាភាសាជប៉ុន៖ **0570-783-578** (គិតថ្លៃហៅចេញ)
ម៉ោងទទួលគឺ 8:30-20:00 រៀងរាល់ថ្ងៃ

## ប្រព័ន្ធលេខបុគ្គល (My Number) បញ្ជរអនឡាញលេខបុគ្គល **Mynaportal**

**0120-0178-26**

### ម៉ោងទទួល

ភាសាអង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ ព័រទុយហ្គាល់ ថៃ នេប៉ាល់ ឥណ្ឌូនេស៊ី វៀតណាម តាកាឡុក

| | |
|---|---|
| **ថ្ងៃធម្មតា** | **9:30 - 20:00** |
| **ចុងសប្តាហ៍និងថ្ងៃបុណ្យជាតិ** | **9:30 - 17:30** |

※ លើកលែងចុងឆ្នាំដើមឆ្នាំ (ថ្ងៃទី 29 ខែធ្នូដល់ថ្ងៃទី 3 ខែមករា)